**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២០១១ ...សហវ-ទីភ

*រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១១*

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម ចំនួន ១ ១៥០ ៨២៧ ៨៤២ រៀល សម្រាប់ជួសជុលប្រព័ន្ធស្រោចស្រពប្រឡាយមេអង្គរទ្រេត ក្នុងឃុំអង្គរទ្រេត ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ។

**យោង:**
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ ០២៣ ធទឧ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនចំនួន ១ ១០៥ ០០០ ០០០ រៀល (មួយពាន់មួយរយប្រាំលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារជួសជុលប្រព័ន្ធស្រោចស្រពប្រឡាយមេអង្គរទ្រេត ក្នុងឃុំអង្គរទ្រេត ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង រួមមាន ៖

- ស្តារប្រឡាយមេអង្គរទ្រេត ប្រវែង ៣.០០០ម
- សំណង់លូស្ទាក់ទឹកមុខកាត់ ១០០ស.ម លើប្រឡាយមេ ចំនួន ០២កន្លែង
- សំណង់លូឆ្លងផ្លូវមុខកាត់ ១០០ស.ម លើប្រឡាយមេ ចំនួន ០១កន្លែង
- សំណង់លូបញ្ចេញទឹកមុខកាត់ ១០០ស.ម លើប្រឡាយមេ ចំនួន ០៦កន្លែង
- សំណង់លូដោះទឹកមុខកាត់ ៦០ស.ម លើប្រឡាយមេ ចំនួន ០៤កន្លែង

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តព្រៃវែង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រៃវែង
- ឯកសារ-កាលប្បវត្តិ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com